ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រម នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បកចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា ១** : ទទួលស្គាល់វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា ដែលមានអក្សរកាត់ "វ.ស.អ.ក" និងជាភាសាអង់គ្លេសថា "Cambodian International Cooperation Institute" ដែលមានអក្សរកាត់

"CICI" ។ វិទ្យាស្ថាននេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅផ្លូវ១៨២ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

**មាត្រា ២** : វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់វិញ្ញាបនបត្រសិក្សារយៈពេលយ៉ាងតិច១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ ត្រូវនឹង៣០ក្រេឌីតឡើងទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង សិក្សារយៈពេលយ៉ាងតិច ២ ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីតឡើងទៅ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ១២០ ក្រេឌីតឡើងទៅ
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាយ៉ាងតិចរយៈពេល ០២ ឆ្នាំ ត្រូវនឹង ៤៥ ក្រេឌីតឡើងទៅ។

**មាត្រា ៣** : ចំពោះមុខវិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យបច្ចេកទេស
- ការិយាល័យសិក្សា
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និងទេសចរណ៍
- មហាវិទ្យាល័យវិស្វកម្ម និងវិទ្យាសាស្ត្រកុំព្យូទ័រ ។

នៅថ្ងៃអនាគតវិទ្យាស្ថាននេះអាចបើកសាខា ឬមហាវិទ្យាល័យ ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៤** : លក្ខខណ្ឌទទួលសិស្ស-និស្សិតឱ្យចូលរៀន ៖

- ថ្នាក់វិញ្ញាបនបត្រ បេក្ខជនជាសិក្ខាកាម សិស្ស-និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទូទៅ
- ថ្នាក់សញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង បេក្ខជនមានវិញ្ញាបនបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ ឬបានប្រឡងជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនមានសញ្ញាបត្របច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

វិទ្យាស្ថានត្រូវគោរពតាមបទដ្ឋាននានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលកំណត់អំពីការជ្រើសរើសការបណ្តុះបណ្តាល ការប្រឡងបញ្ចប់ការសិក្សារបស់សិស្ស-និស្សិត ។

**មាត្រា ៥** : វិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា មាននាយកមួយរូប និងមាននាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងរយៈពេលមួយឆមាសម្តងឱ្យបានទៀងទាត់តាមការកំណត់ ។

**មាត្រា ៦** : សិស្ស-និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ នឹងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឲ្យដោយវិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ៧** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួងអប់រំយុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យលោកជំទាវឧបនាយករដ្ឋមន្ត្រីប្រចាំការ
- គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- គ្រប់ខេត្ត-រាជធានី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ